ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៦៦......សហវ.ប្រក

# ប្រកាស
# ស្តីពី
# សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អភិបាលថវិកា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អភិបាលថវិកា ដើម្បីចូលរួមចំណែកធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព នៃការត្រួតពិនិត្យការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល មន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងគ្រឹះស្ថានជារណៈរដ្ឋបាល ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការត្រួតពិនិត្យថវិការបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល មន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងគ្រឹះស្ថានជារណៈរដ្ឋបាល ។

## ជំពូកទី ២

## អភិបាលថវិកា និងសិទ្ធិអំណាច

**ប្រការ៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអភិបាលថវិកា ដែលមានសិទ្ធិក្នុងការពិនិត្យនិងផ្តល់ទិដ្ឋាការធានាចំណាយនិងអាណត្តិបើកប្រាក់ និងលើសំណើចំណាយផ្សេងៗទៀត របស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល មន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

## ជំពូកទី ៣

## ការប្រគល់សិទ្ធិ និងការទទួលខុសត្រូវ

**ប្រការ៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចប្រគល់សិទ្ធិជាអភិបាលថវិកា ជូនថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកនិងថ្នាក់ដឹកនាំពាក់ព័ន្ធនៃអគ្គនាយកដ្ឋានថវិកា, ប្រធានអង្គភាពត្រួតពិនិត្យថវិកា, មន្ត្រីត្រួតពិនិត្យថវិកាប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល និងប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៥.-**

ការប្រគល់សិទ្ធិជាអភិបាលថវិកា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៦.-**

ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ ដែលទទួលបានការប្រគល់សិទ្ធិជាអភិបាលថវិកាដូចចែងក្នុងប្រការ៤ នៃប្រកាសនេះ ពិនិត្យនិងផ្តល់ទិដ្ឋាការធានាចំណាយ អាណត្តិបើកប្រាក់ និងលើសំណើចំណាយផ្សេងៗទៀតរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល មន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងគ្រឹះស្ថានជារណៈរដ្ឋបាល តាមមុខសញ្ញាចំណាយ និងតាមកម្រិតទឹកប្រាក់ ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រគល់សិទ្ធិ ។ ក្នុងករណីសំណើសុំចំណាយរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល មន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត និងគ្រឹះស្ថានជារណៈរដ្ឋបាល មានទឹកប្រាក់ និងមុខសញ្ញាចំណាយ មិនស្ថិតក្រោមសិទ្ធិ ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រគល់ជូន អភិបាលថវិកាត្រូវផ្តល់យោបល់ឱ្យបានត្រឹមត្រូវជាលាយលក្ខណ៍អក្សរ ដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ។

**ប្រការ៧.-**

ក្នុងករណីសំណើសុំចំណាយដែលនៅក្រោមសិទ្ធិមានវេទយិតភាពខ្ពស់ អភិបាលថវិកាដែលទទួលបានការប្រគល់សិទ្ធិ ត្រូវស្នើសុំការពិនិត្យនិងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ។

**ប្រការ៨.-**

ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបានការប្រគល់សិទ្ធិជាអភិបាលថវិកាពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវប្រគល់សិទ្ធិជាអភិបាលថវិកាជូនថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្សេងទៀត នៅពេលអវត្តមានឬមានធុរៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ចំពោះមន្ត្រីពាក់ព័ន្ធផ្សេងទៀត ដែលទទួលបានការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវប្រគល់សិទ្ធិជាអភិបាលថវិកា ជូនថ្នាក់ដឹកនាំ ឬមន្ត្រីក្រោមឱវាទមួយរូប នៅពេលអវត្តមានឬមានធុរៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៩.-**

អភិបាលថវិកាដែលទទួលបានការប្រគល់សិទ្ធិ ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរាល់កិច្ចការរបស់ខ្លួន ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ១១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាននិងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១៣ កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ